ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

**សំណុំរឿងព្រហ្មទណ្ឌ**

លេខៈ ៥៨៤

ចុះថ្ងៃទី ០៩-០៥-២០២២

**សាលដីកា**

លេខៈ ៧៩ "ក្រVI.ស.អ"

ចុះថ្ងៃទី ០៥-០៧-២០២២

# តាមនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខៈ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាឧទ្ធរណ៍ភ្នំពេញនាថ្ងៃអង្គារ ៧កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័កព.ស.២៥៦៦ត្រូវនឹងថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ ដោយមានសមាសភាពដូចតទៅៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខៈ ៥៨៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ ២០២២ ដែលមានៈ

១-ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ៣៧ឆ្នាំ សញ្ជាតិខ្មែរ កន្លែងកំណើតនៅសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ លំនៅមុនពេលឃុំខ្លួនស្នា[redacted] ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] សុភា មានកូនចំនួន ០១នាក់ ឪពុកឈ្មោះ[redacted] សារ៉ា (ស) ម្តាយឈ្មោះ[redacted] ប៉ូ(រ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ *(ប្តឹងឧទ្ធរណ៍)*

*-ឃុំខ្លួននៅពន្ធនាគារភ្នំពេញ(PJ) តាមដីកាបង្គាប់លេខៈ ៩១៧១ "ឆ១" ដ.យ.ដ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ ។*

<u>ជាប់ចោទពីបទ</u> **រក្សាទុក ដឹកជញ្ជូន ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទ សម្អាតប្រាក់** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០, ៧០, ៧១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

មានមេធាវី[redacted]ណ្ណឌី និងមេធាវី[redacted] សុវណ្ណដារ៉ា ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] ពិសិដ្ឋ ។

២-ជនជាប់ចោទឈ្មោះ[redacted] ពន្លក ភេទប្រុស អាយុ៣១ឆ្នាំ សញ្ជាតិខ្មែរ កន្លែងកំណើតភូមិស្រែគោក ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល លំនៅមុនពេលឃុំខ្លួនភូមិស្រែ[redacted] កណ្តាលស្ទឹង ខេត្តកណ្តាល ពោះម៉ាយមានកូនចំនួន០១នាក់ ឪពុកឈ្មោះ[redacted] (ស) ម្តាយឈ្មោះ[redacted]

[redacted] ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។ *(ប្តឹងឧទ្ធរណ៍)*

*-ឃុំខ្លួននៅពន្ធនាគារភ្នំពេញ(PJ)តាមដីកាបង្គាប់លេខ: ៨១៧០ "ឆ១" ដ.ឃ.ដ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ ។*

<u>ជាប់ចោទពីបទ</u> **រក្សាទុក ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន និងបទ សម្គាត់ប្រាក់** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០, ៧០, ៧១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

មានមេធាវី [redacted] ច័ន្ទសុវណ្ណដា ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ពន្លក ។

៣-ជនជាប់ចោទឈ្មោះ [redacted] សួស្តី ហៅ ពៅ ភេទប្រុស កើតឆ្នាំ១៩៨២ សញ្ជាតិខ្មែរ កន្លែងកំណើតសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ លំនៅបច្ចុប្បន្នស្នាក់នៅ [redacted] អប់រំកែប្រែទី១ ប្រពន្ធឈ្មោះ [redacted] (លែងលះ) មានកូនចំនួន ០៣នាក់ ឪពុកឈ្មោះ [redacted] ) ម្តាយឈ្មោះ [redacted] ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ ជាប់ចោទពីបទ ប្លន់សម្លាប់ ផ្តន្ទាទោសអស់មួយជីវិត ។

*-ឃុំខ្លួននៅ មទ តាមដីកាបង្គាប់លេខ: ៨១៧២ "ឆ១" ដ.ឃ.ដ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ ។*

<u>ជាប់ចោទពីបទ</u> **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

មានមេធាវី [redacted] គីមហួយ, មេធាវី [redacted] ចំរើន និងមេធាវី [redacted] ស៊ុន ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សួស្តី ។

## <u>អំពីអង្គហេតុ</u>

កាលពីអំឡុងឆ្នាំ២០១៤ ឈ្មោះ [redacted] ពិសិដ្ឋ បានរកស៊ីជួញដូរគ្រឿងញៀន និងដឹកជញ្ជូនគ្រឿងញៀនឲ្យម៉ូយតាមការបញ្ជារបស់ឈ្មោះ Na Kali (ឈ្មោះក្នុងហ្វេសបុក) បានចំនួន ០៤លើក ដោយទទួលបានកម្រៃជើងសារក្នុង ០១គីឡូ តម្លៃ ១០០ ដុល្លារអាមេរិក ។ ឈ្មោះ [redacted] ពិសិដ្ឋ ក៏បានទិញគ្រឿងញៀនពីឈ្មោះ Na Kali បានចំនួនប្រហែល ០៤លើក តាមរយៈលេខទូរស័ព្ទ [redacted] ដើម្បីលក់បន្តទៅឲ្យម៉ូយ ។ ចំពោះប្រាក់ដែលបានពីការលក់ និងដឹកជញ្ជូនគ្រឿងញៀនឲ្យម៉ូយនោះឈ្មោះ [redacted] ពិសិដ្ឋ បានយកទៅទិញដីឡូតិ៍លេខD2 ទំហំ 70m$^2$ ស្ថិតនៅភូមិជាងទង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដូចមានក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ: ២៥៤១ លប.កព្រ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់អភិបាលខណ្ឌសែនសុខ និងទិញម៉ូតូមួយគ្រឿងម៉ាក HONDA PCX 150 ពណ៌ស ស្លាកលេខ ស្វាយរៀង 1P-9730 ។ លុះនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ ឈ្មោះ Na Kali បានទំនាក់ទំនងមកឈ្មោះ [redacted] ពិសិដ្ឋ ឲ្យចាំយកគ្រឿងញៀនដែលគេបានផ្ញើមកឲ្យម៉ូយដូចរាល់ដង ។ បន្ទាប់មកឈ្មោះ [redacted] ពិសិដ្ឋ ក៏បានចាំយកគ្រឿងញៀននៅចំណុចដីឡូតិ៍ទុកចោល ក៏ត្រូវសមត្ថកិច្ចត្រួតពិនិត្យឆែកឆេរឃើញមានថ្នាំញៀនមួយចំនួន គាប់ជួនឈ្មោះ [redacted] ពន្លក ក៏ទំនាក់ទំនងមកឈ្មោះ [redacted] ពិសិដ្ឋ ថាខ្លួនបានយកអីវ៉ាន់មកឲ្យតាមរយៈឈ្មោះ [redacted] សួស្តី ហៅ ពៅ ជាអ្នកឲ្យយកមកដោយបានណាត់ជួបគ្នាយកគ្រឿងញៀននៅម៉ូឌែន៥ ។ ឈ្មោះ [redacted] ពន្លក បានជិះឡានម៉ាក TOYOTA CAMRY 150 ពណ៌ខ្មៅ ស្លាកលេខ 2T-6441 ដឹកបាវចំនួន ០៣ មកដល់គោលដៅណាត់ជួបក៏ត្រូវមានសមត្ថកិច្ចត្រួតពិនិត្យរកឃើញបាវចំនួន ០៣ (ដែលក្នុងបាវនោះមានត្រីងៀត ដោយបង្កប់គ្រឿងញៀនក្នុងនោះផងដែរ) ។ បន្ទាប់មកសមត្ថកិច្ចបានធ្វើការឃាត់ខ្លួន និងដកហូតវត្ថុតាងរួមមាន៖ ១-ហិបដែកចំនួន០១ ពណ៌ទឹកប្រាក់ ដែលមានកំណត់ហេតុបិទកេសដែកជាវត្ថុតាងលេខ ២៣១ កណហ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ ដោយមានស្នាមមេដៃស្តាំឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] ពន្លក និងហត្ថលេខាគណៈកម្មការដោយកំណត់ហេតុបញ្ជាក់ថា វត្ថុតាងដកហូតបានបីគោលដៅ ។ គោលដៅទី១ ក្រោមពណ៌សថ្លា

ទម្ងន់១០០(មួយរយ)ក្រាម (មេតំហ្វេតាមីន) ជារបស់ឈ្មោះ [redacted] ពិសិដ្ឋ ។ គោលដៅទី២ ជារបស់ឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] ពន្លក មានៈ ក-ក្រាមពណ៌សថ្លាទម្ងន់សរុប២៩៩៤០ (ពីរម៉ឺនប្រាំបួនពាន់ប្រាំបួនរយសែសិប)ក្រាម តែបានដកទម្ងន់២២,៤៧ (ម្ភៃពីរកណ្ដាក់សញ្ញាសែសិបប្រាំពីរ)ក្រាម ជូនទៅក្រុមការងារចំពោះកិច្ច ។ ខ-ក្រាមពណ៌ស ទម្ងន់សរុប១៩៩៤៦,៦៦(មួយម៉ឺន ប្រាំបួនពាន់ប្រាំបួនរយសែសិបប្រាំមួយកណ្ដាក់សញ្ញាហុកសិបប្រាំមួយ)ក្រាម តែបានដកទម្ងន់៦៦.៩២ (ហុកសិបប្រាំមួយកណ្ដាក់សញ្ញាកៅសិបពីរ) ក្រាម ជូនទៅក្រុមការងារចំពោះកិច្ច ។ គោលដៅទី៣ ក្រាមពណ៌សថ្លាទម្ងន់៣០០(បីរយ)ក្រាម (មេតំហ្វេតាមីន) ជារបស់ឈ្មោះ [redacted] ពិសិដ្ឋ ។ តាមកំណត់ហេតុខាងលើនេះឃើញថា សមត្ថកិច្ចក៏បានដកហូតនូវវត្ថុតាង និងសម្ភារៈមួយចំនួនទៀត ។ តាមចម្លើយសារភាពរបស់ឈ្មោះ [redacted] ពិសិដ្ឋ បង្ហាញថាឈ្មោះ [redacted] ពិសិដ្ឋ បានរកស៊ីលក់ដូរថ្នាំញៀនតាំងពីអំឡុងឆ្នាំ២០១៤ ហើយចំពោះប្រាក់ដែលបានមកពីការលក់គ្រឿងញៀនបានយកទៅទិញដីឡូត៍លេខD2 ទំហំ70ម៉ែត្រការ៉េ ទីតាំងស្ថិតនៅភូមិជាងទង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដូចមានក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ២៥៤១ លប.កព្រ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់អភិបាលខណ្ឌសែនសុខ និងទិញម៉ូតូ០១គ្រឿងម៉ាក HONDA PCX 150 ពណ៌ស ស្លាកលេខស្វាយរៀង 1P-9730 ចំណែកប្រាក់នៅសល់បានចំណាយផ្គត់ផ្គង់ក្នុងជីវភាពគ្រួសារ ។ ឈ្មោះ [redacted] ពិសិដ្ឋ ក៏បានទទួលស្គាល់ផងដែរថាខ្លួនបានដឹកគ្រឿងញៀនយកទៅឲ្យម៉ូយតាមបញ្ជារបស់ឈ្មោះ Na Kali (ឈ្មោះក្នុងហ្វេសប៊ុក) បានចំនួន០៤លើក ។ តាមចម្លើយរបស់ឈ្មោះ [redacted] ពន្លក ក៏បានបង្ហាញផងដែរថាកាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ ឈ្មោះ [redacted] ពន្លក បានដឹកបាវចំនួន០៣ ដែលក្នុងនោះមានត្រីងៀតបង្កប់គ្រឿងញៀនពីខាងក្នុងទៅឲ្យឈ្មោះ [redacted] ពិសិដ្ឋ នៅម្ដុំម៉ូខែន៥តាមការបញ្ជារបស់ឈ្មោះ [redacted] សួស្ដី ហៅ ពៅ ។ ចំពោះកម្រៃដែលបានពីការដឹកជញ្ជូនថ្នាំញៀននោះគេបានយកទៅទិញឡានមួយគ្រឿងម៉ាក TOYOTA CAMRY 150 ពណ៌ខ្មៅស្លាកលេខ2T-6441 ។ បន្ទាប់ពីធ្វើការសាកសួរសមត្ថកិច្ចក៏បានកសាងសំណុំរឿងបញ្ជូនមកកាន់សាលាដំបូងរាជធានីភ្នំពេញដើម្បីចាត់ការតាមនីតិវិធី ។

***បានឃើញ*** *សាលក្រមព្រហ្មទណ្ឌលេខៈ ១៦៦ "ខ១"ក្រ៨ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ*

១-ផ្ដន្ទាទោសឈ្មោះ [redacted] ពន្លក ភេទប្រុស អាយុ៣១ឆ្នាំ ដែលមានអត្តសញ្ញាណខាងលើដាក់ពន្ធនាគារកំណត់ ***២៣(ម្ភៃបី)ឆ្នាំ*** និងពិន័យជាប្រាក់ចំនួន៤០.០០០.០០០(សែសិបលាន) រៀល ពីបទ រក្សាទុក ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន និងបទ សម្អាតប្រាក់ ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤០ មាត្រា៧០ និងមាត្រា៧១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-ផ្ដន្ទាទោសឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ៣៧ឆ្នាំ ដែលមានអត្តសញ្ញាណខាងលើដាក់ពន្ធនាគារកំណត់ ***២៥(ម្ភៃប្រាំ)ឆ្នាំ*** និងពិន័យជាប្រាក់ចំនួន៦០.០០០.០០០(ហុកសិបលាន)រៀល ពីបទ រក្សាទុក ដឹកជញ្ជូន ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទ សម្អាតប្រាក់ ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤០ មាត្រា៧០ និងមាត្រា៧១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-ផ្ដន្ទាទោសឈ្មោះ [redacted] សួស្ដី ហៅ ពៅ ភេទប្រុស កើតឆ្នាំ១៩៨២ ដែលមានអត្តសញ្ញាណខាងលើដាក់ពន្ធនាគារកំណត់ ***៣០(សាមសិប)ឆ្នាំ*** និងពិន័យជាប្រាក់ចំនួន៨០.០០០.០០០(ប៉ែតសិបលាន) រៀល ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

៤-រឹបអូសវត្ថុចាប់យក និងទ្រព្យសម្បត្តិដូចខាងក្រោមៈ

-ដីឡូត៍លេខD2 ទំហំ៧០ម² មានទីតាំងស្ថិតនៅភូមិដាំងទង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ សម្គាល់ដោយលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ២៥៤១ លប.កព្រ ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ចេញដោយសាលាខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

-ម៉ូតូម៉ាក HONDA PCX 150 ពណ៌ស ចំនួន០១គ្រឿង ពាក់ស្លាកលេខស្វាយរៀង 1P-9730 ។

-រថយន្តម៉ាក TOYATA CAMRY ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 2T-6441 ។

-ទូរស័ព្ទម៉ាកOPPO ពណ៌ខៀវ (IMEI 867218050712116) ០១គ្រឿង ។

-ទូរស័ព្ទម៉ាកSAMSUNG (IMY48BJ700KKU1ARK2) ចំនួន០១គ្រឿង ។

-ទូរស័ព្ទម៉ាកOPPO (IMEI 862627059728938) ចំនួន០១គ្រឿង ។

-ក្រាមពណ៌សថ្លាមានផ្ទុកសារធាតុញៀន ប្រភេទមេតំហ្វេតាមីន នៅសល់ពីការដកហូតធ្វើកោសលវិច័យ (ទម្ងន់មុនពេលដកហូត១០០ក្រាម) ។

-ក្រាមពណ៌សថ្លាមានផ្ទុកសារធាតុញៀន ប្រភេទមេតំហ្វេតាមីន នៅសល់ពីការដកហូតធ្វើកោសលវិច័យ (ទម្ងន់មុនពេលដកហូត២៩៩៤០ក្រាម) ។

-ក្រាមពណ៌សថ្លាមានផ្ទុកសារធាតុញៀន ប្រភេទកេតាមីន នៅសល់ពីការដកហូតធ្វើកោសលវិច័យ (ទម្ងន់មុនពេលដកហូត១៩៩៤៦.៦៦ក្រាម) ។

-ក្រាមពណ៌សថ្លាមានផ្ទុកសារធាតុញៀន ប្រភេទមេតំហ្វេតាមីន នៅសល់ពីការដកហូតធ្វើកោសលវិច័យ (ទម្ងន់មុនពេលដកហូត៣០០ក្រាម) ។

-កញ្ចប់ថង់ប្លាស្ទិកប្រកគ្រឿងញៀនពណ៌ខៀវ១៦កញ្ចប់ និង០២កំណាត់ ។

-ថង់ប្លាស្ទិកសថ្លាចំនួន០៣កញ្ចប់ ។

-ដាវកែច្នៃ០១ដើម ។

-សម្ភារៈសម្រាប់ប្រើប្រាស់គ្រឿងញៀនថង់ក្រដាសពណ៌ផ្កាឈូក និងថង់ក្រណាត់មួយចំនួន ។

-សៀវភៅសរសេរម៉ាកស៊្រិន ងួន(SNG-70SN) ១៤០ទំព័រ០១ក្បាល ។

-សៀវភៅសរសេរគ្មានក្របខ០១ក្បាល ។

-កូនសៀវភៅលេខទូរស័ព្ទ០១ក្បាល ។

-ក្រដាសកត់ត្រាលេខទូរស័ព្ទមួយចំនួន ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៥៤៤២៦៤(០១) ថតចម្លង ។

-ប័ណ្ណសម្គាល់ទោចក្រយានយន្តចំនួន០១( ស្វាយរៀង 1P-9730) ថតចម្លង ។

-ស្លាកលេខម៉ូតូចំនួន០២ (ភ្នំពេញ 1GQ-0844) (ភ្នំពេញ 1HS-8441) ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]តិសិទ្ធ ឈ្មោះ[redacted]ពន្លក និងឈ្មោះ[redacted]សួស្តី ហៅ ពៅ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**បានឃើញ** សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខៈ ២៨៤ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted]សួស្តី សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ១៦៦ "ខ១"ក្រ៨ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច *ទាំងមូលនៃសេចក្តីសម្រេច* ។

**បានឃើញ** សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខៈ ៣៦៩ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ពន្លក សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ១៦៦ "ខ១"ក្រ៨ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច *ទាំងមូលនៃសេចក្តីសម្រេច* ។



Scanned with CamScanner

**បានឃើញ** សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខៈ ៣៨៥ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ សុំប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ១៦៦ "ខ១"ក្រ៨ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច *ទាំងមូលនៃសេចក្ដីសម្រេច*។

**បានឃើញ** របាយការណ៍សំណុំរឿងព្រហ្មទណ្ឌ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ។

**បានឃើញ** សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ។

**បានឃើញ** សារណាការពាររបស់មេធាវី ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ របស់មេធាវី [redacted]គីមហួយ ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សួស្ដី ។

## <u>នាពេលសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ</u>

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះប្រាប់សិទ្ធិជនជាប់ចោទ និងអានរបាយកាណ៍អំពីរឿងក្ដី ។

-ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បានឆ្លើយថាៈ សាលាដំបូងផ្ដន្ទាទោសខ្លួនចំនួន ២៥ឆ្នាំ គឺមានលក្ខណៈធ្ងន់ធ្ងរពេក ខ្លួនទទួលស្គាល់ចម្លើយដែលបានឆ្លើយនៅសាលាដំបូង ។ ខ្លួនជាប់ឃុំខ្លួនរយៈពេល១១ខែ ហើយសុំតុលាការមេត្តាផ្ដល់ស្ថានសម្រាលទោសឲ្យខ្លួនផង ។ ឈ្មោះ ណាកាលី គឺជាអ្នកជួលខ្លួនឲ្យដឹកឥវ៉ាន់ឲ្យតាមរយៈទូរស័ព្ទ ខ្លួនមិនដែលបានជួបផ្ទាល់ទេ ។ គេគ្រាន់តែប្រាប់ទីតាំងដែលត្រូវយកផ្សេងៗគ្នា ពេលដែលគាត់ស៊ីយកមកឲ្យខ្លួនយកទៅបោះឲ្យម៉ូយភ្លាមៗ ខ្លួនដឹកឲ្យគេម្ដងទទួលបានកម្រៃ១០០ដុល្លារ សរុបបានចំនួន៤លើកហើយ ។ ចំពោះផ្ទះដែលតុលាការសម្រេចរឹបអូសនេះគឺជាលុយផ្ទាល់ខ្លួនរបស់ម្ដាយខ្លួន មិនមែនជាលុយរបស់ខ្លួនទេ ។ ពេលសមត្ថកិច្ចឃាត់ខ្លួនក៏មានគេខលទូរស័ព្ទឲ្យទៅយកឥវ៉ាន់ប៉ុន្តែខ្លួនមិនបានដឹងថាជាអ្វីទេ មានចំនួន៣កេះ ហើយអ្នកផ្ញើក៏មិនបានប្រាប់ឈ្មោះដែរចំណែកអ្នកទទួលក៏ពុំបានស្គាល់ឈ្មោះដែរ ។

-ជនជាប់ចោទឈ្មោ[redacted]ពន្លក បានឆ្លើយថាៈ ខ្លួនទទួលស្គាល់ចម្លើយនៅសាលាដំបូងរាជធានីភ្នំពេញ ខ្លួនមិនបានដឹងរឿងទេ គេជួលឲ្យដឹកឲ្យប្រាក់ចំនួន ៣ ០០០ដុល្លារអាមេរិក កន្លងមកខ្លួនមិនដែលដឹកទេទើបជាលើកទី១ ខ្លួនមានមុខរបរជាជាងជួសជុលម៉ូតូ ចំណែកឡាននោះគឺជួលគេតម្លៃ១០០ដុល្លារ ។ ពេលនោះកូវីដខ្លួនក៏មិនមានចំណូលហើយគេហៅជួលដឹកឥវ៉ាន់ខ្លួនក៏ព្រម ។ ខ្លួនស្គាល់ឈ្មោះ ពៅ តាមរយៈបងរបស់ខ្លួនដោយសាគាត់ជាមិត្តភក្តិរបស់បងខ្លួន ។ ដំបូងឡើយខ្លួនទាក់ទងតាមទូរស័ព្ទដៃក្រោយមកក៏ទាក់ទងគ្នាតាមឆាត ។ ឡាននេះខ្លួនដឹកឥវ៉ាន់តែ៣ការ៉ុងនេះទេមិនមានដឹកអ្វីផ្សេងទៀតទេ គាត់ចាំពេលដឹកមកដល់គាត់ឲ្យលុយបើកកន្លែងជួសជុលម៉ូតូ ចំពោះឈ្មោះ ពិសិដ្ឋ ទើបតែស្គាល់នៅពេលដែលសមត្ថកិច្ចឃាត់ខ្លួននេះទេ ។ ខ្លួនមានអាសយដ្ឋាននៅភ្នំពេញខ្លួនបើទៅយកឥវ៉ាន់នៅខេត្តក្រចេះ ប៉ុន្តែយប់វង្វេងផ្លូវហួសទៅដល់ខេត្តស្ទឹងត្រែង នៅពេលដែលសមត្ថកិច្ចឃាត់ខ្លួនធ្វើការឆែកឆេរឃើញថា ជាថ្នាំញៀនខ្លួនភ័យយ៉ាងខ្លាំងទើបដឹងថាចាញ់បោកគេ ។ ទទួលទើបតែទទួលបានសោរ ៥០០ ដុល្លារទេ នៅសល់ចំនួន ២៥០០ដុល្លារទៀតមិនទាន់បានទទួលទេ ។ ចំពោះឈ្មោ[redacted]សួស្ដី ខ្លួនទើបតែជួបមុខនៅពេលសមត្ថកិច្ចឃាត់ខ្លួនទេ ។ ខ្លួនមិនដែលដឹកឥវ៉ាន់ទេ ទើបតែដឹកជាលើកទី១ ខ្លួនមិនដឹងច្បាស់ថាឈ្មោះ[redacted]សួស្ដី និងឈ្មោះ ពៅ គឺជាមនុស្សតែម្នាក់ ឬអត់ទេ ។ ចំពោះឥវ៉ាន់នេះគេប្រាប់ថាជាត្រីងៀត ខ្លួនក៏មិនដឹងថាជាអ្វីដែរ ហើយក៏មិនបានបើកមើលដែរ ។

-ជនជាប់ចោទឈ្មោះ[redacted]សួស្ដី បានឆ្លើយថាៈ ខ្លួនទទួលស្គាល់ចម្លើយដែលបានឆ្លើយនៅសាលាដំបូងទុកបានការដដែល ខ្លួនទទួលស្គាល់អង្គហេតុដូចការចោទប្រកាន់មែន ។ គ្រឿងញៀនទាំងនេះគឺយកពីខេត្តស្ទឹងត្រែងមក ខ្លួនរកស៊ីនេះ ២ ទៅ៣ ដងហើយ ខ្លួនក៏ស៊ីឈ្នួលដឹកយកឲ្យគេដែរ ទទួលបានកម្រៃមួយជើង ៦ ០០០ ទៅ ៧ ០០០ដុល្លារអាមេរិក ។ ក្រៅពីមុខរបរនេះខ្លួនមិនមានមុខរបរអ្វីផ្សេងទៀតទេ ខ្លួនមានប្រពន្ធកូនហើយ

ខ្លួនទើបតែឲ្យឈ្មោះ [redacted] ពន្លក ដឹកជាលើកទី១ ហើយក៏មិនបានប្រាប់ថាជាអ្វីដែរ គាត់បានសួរតែខ្លួនប្រាប់ថាជាត្រីងៀត ។ ខ្លួនទើបតែឲ្យប្រាក់ថ្លៃឈ្នួលបានចំនួន ៥០០ដុល្លារទេ ។ ចំពោះត្រីងៀតទាំងនេះមានតម្លៃប្រហែល ១ ០០០ ០០០រៀល ។ ខ្លួនស្គាល់ឈ្មោះ [redacted] ពន្លក តាមរយៈបងរបស់វាឈ្មោះ បូរ ដែលជាមិត្តភក្តិរៀនជាមួយគ្នា តែបានស្លាប់បាត់ហើយ ។ ខ្លួនមិនចាំថាចំនួនគ្រឿងញៀនដែលដកហូតបាននោះមានចំនួនប៉ុន្មានទេ គ្រាន់តែដឹងថាមានចំនួនច្រើនជាងបីម៉ឺនក្រាម ។ ខ្លួនទទួលស្គាល់អង្គហេតុខ្លួនបានដឹងកំហុសហើយសន្យាឈប់ប្រព្រឹត្តទៀតហើយ ។ ខ្លួនបញ្ជារចេញពីក្នុងពន្ធនាគារ ចំពោះសំណុំរឿងមុនផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។ សំណូមពរសូមតុលាការមេត្តាសម្រេចបន្ថយទោសឲ្យខ្លួនផង ។

-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់របាយការណ៍ និងក្រោយពីបានស្តាប់កិច្ចពិភាក្សាដេញដោលយល់ឃើញថា សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ: ២៨៤ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] សួស្តី, លេខ: ៣៦៩ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ពន្លក និងលេខ: ៣៨៥ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ១៦៦ "ខ១"ក្រ៨ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ គឺធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងតាមមាត្រា៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ។ មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ ជាករណីជាក់ស្តែងដែលចាប់ឃាត់ខ្លួនជនជាប់ចោទ និងដកហូតបានថ្នាំញៀនពីជនជាប់ចោទ ដែលស៊ីសង្វាក់គ្នាជាមួយចម្លើយរបស់ជនជាប់ចោទគ្រប់ដំណាក់កាល ។ តាមសាលក្រមព្រហ្មទណ្ឌលេខ: ១៦៦ "ខ១"ក្រ៨ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញបានសម្រេចផ្តន្ទាទោសឈ្មោះ [redacted] ពន្លក ដាក់ពន្ធនាគារកំណត់ *២៣ឆ្នាំ* ពិន័យជាប្រាក់ចំនួន៤០ ០០០ ០០០ រៀល, ឈ្មោះ [redacted] ពិសិដ្ឋ ដាក់ពន្ធនាគារកំណត់ *២៥ឆ្នាំ* ពិន័យជាប្រាក់ចំនួន ៦០ ០០០ ០០០ រៀល និងឈ្មោះ [redacted] សួស្តី ហៅ ពៅ ដាក់ពន្ធនាគារកំណត់ *៣០ឆ្នាំ* ពិន័យជាប្រាក់ចំនួន ៨០ ០០០ ០០០រៀល ។ ឃើញថាសាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងសម្រេចផ្តន្ទាទោសត្រឹមកម្រិតអប្បរមានរួចហើយ ហេតុនេះស្នើសុំតម្កល់ទុកបានការដែល ។

-មេធាវី [redacted] វណ្ណឌី ការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្លួនបានដឹងកំហុងហើយបានទទួលស្គាល់កំហុសហើយ ចំពោះកម្រៃដែលគាត់ទទួលបានគឺតិចតួចបំផុតគឺមានចំនួនតែ៤០០ដុល្លារ ប៉ុណ្ណោះ ហើយគាត់ដឹកតាមការបញ្ជារបស់ឈ្មោះ ណាកាលី ទេ ។ ចំពោះដីឡូតិ៍លេខ D2 ទំហំ៧០ម៉ែត្រការ៉េ ដែលតុលាការសម្រេចរឹបអូសនេះគឺជាកម្មសិទ្ធិរបស់ម្តាយកូនក្តីខ្លួនដែលបានចំណាយប្រាក់ផ្ទាល់ខ្លួនរបស់គាត់ទិញពីឈ្មោះ [redacted] ឈុនគ្រី មានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវតាំងពីឆ្នាំ២០១៤ ។ សំណូមពរសូម បន្ថយទោសឲ្យកូនក្តីខ្លួនដោយក្តីអនុគ្រោះ ។

-មេធាវី [redacted] សុវណ្ណដារ៉ា ការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: ខ្លួនសូមឯកភាពតាមសេចក្តីសន្និដ្ឋានរបស់សហភាគា ។

-មេធាវី [redacted] ច័ន្ទសុវណ្ណដា ការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្លួនពុំបានជាប់ពាក់ព័ន្ធជាមួយបទល្មើសសម្អាតប្រាក់ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនទេ ។ ឈ្មោះ ពៅ បានទាក់ទងមកកូនក្តីខ្លួនតាមរយៈបងជីដូនមួយគាត់ ហើយគាត់ប្រាប់ថាគឺជាត្រីងៀតបើដឹងថាជាថ្នាំញៀនក៏កូនក្តីខ្លួនមិនដឹកដែរ ។ កូនក្តីខ្លួនមានមុខរបរជាជាងជួសជុលម៉ូតូដោយសារតែវិបត្តិកូវីដមិនមានចំណូលហើយមានគេជួលទើបគាត់ទៅរកជួលឡានគេដើម្បីមកស៊ីឈ្នួលដឹកឥវ៉ាន់ឲ្យគេ ។ ចំពោះឈ្មោះ [redacted] ពិសិដ្ឋ គាត់ពុំដែលស្គាល់ទេទើបតែស្គាល់ពេលសមត្ថកិច្ចឃាត់ខ្លួនប៉ុណ្ណោះ ហើយគាត់ក៏មិនបានដឹងថាគេឲ្យដឹកនោះជាថ្នាំញៀនដែរទើបតែដឹងនៅពេលសមត្ថកិច្ចឃាត់ខ្លួនប្រាប់ថាចាញ់បោកគេគាត់មានការភ័យយ៉ាងខ្លាំង ។ ឈ្មោះ ពៅ ក៏បានបញ្ជាក់រួច

ហើយថាគាត់ប្រាប់កូនក្ដីខ្លួនថាជាត្រីងៀតមិនមែនជាថ្នាំញៀនទេ ។ កូនក្ដីខ្លួនបានឆ្លើយបដិសេធរហូតមកគាត់គ្រាន់តែដឹងឥវ៉ាន់ដែលដឹកជាត្រីញៀតប៉ុណ្ណោះគាត់មិនបានពាក់ព័ន្ធជាមួយបទល្មើសទេ ហើយក៏ពុំមានភស្តុតាងបញ្ជាក់ថាគាត់មានការពាក់ព័ន្ធទេ ។ សំណូមពរសូមឲ្យកូនក្ដីខ្លួនរួចផុតពីបទចោទប្រកាន់ ។

-មេធាវី [redacted] ស៊ុន ការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថាៈ កូនក្ដីខ្លួនបានឆ្លើយសារភាពទទួលស្គាល់កំហុសហើយ គាត់មិនបានបង្កឧបសគ្គដល់នីតិវិធីតុលាការទេ កូនក្ដីខ្លួនមានជីវភាពក្រីក្រ មានប្រពន្ធកូនក្នុងបន្ទុកសំណូមពរសូមតុលាការមេត្តាផ្ដល់ស្ថានសម្រាលដល់កូនក្ដីខ្លួនដោយក្ដីអនុគ្រោះ ។

-មេធាវី [redacted] គីមហួយ ការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថាៈ កូនក្ដីខ្លួនបានសហការជាមួយតុលាការ និងបានឆ្លើយសារភាពទទួលស្គាល់កំហុសហើយជួយតុលាការធ្វើកិច្ចស៊ើបអង្កេតប្រព្រឹត្តទៅបានយ៉ាងរលូន ។ គាត់បានដឹងកំហុសហើយសន្យាកែខ្លួនសូមតុលាការមេត្តាផ្ដល់ស្ថានសម្រាលទោសដល់កូនក្ដីខ្លួនដោយក្ដីអនុគ្រោះ ។

-ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ឈ្មោះ [redacted] ពន្លក និងឈ្មោះ [redacted] សួស្ដី បានសំណូមពរថាៈ សូមតុលាការមេត្តាផ្ដល់ស្ថានសម្រាលទោសឲ្យពួកខ្លួនដោយអនុគ្រោះ ។

-ក្រោយពីបានស្ដាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់ជនជាប់ចោទ និងមេធាវីការពារសិទ្ធិ

-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្ដី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍ភ្នំពេញយល់ឃើញថា

១-តាមសេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខៈ ២៨៤ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] សួស្ដី, សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខៈ ៣៦៩ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ពន្លក និងសេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខៈ ៣៨៥ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ស៊ុំប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ១៦៦ "ខ១" ក្រ៨ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច គឺធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ អាចទទួលសំណុំរឿងព្រហ្មទណ្ឌខាងលើនេះមកជំនុំជម្រះ បានយោងតាមមាត្រា៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា៣៨២ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-តាមសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការបានលើកឡើងថាៈ បណ្ដឹងឧទ្ធរណ៍លេខៈ ២៨៤ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] សួស្ដី, លេខៈ ៣៦៩ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ពន្លក និងលេខៈ ៣៨៥ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ គឺធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងតាមមាត្រា៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា៣៨២ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ។ មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ ជាករណីជាក់ស្ដែងឃាត់ខ្លួនជនជាប់ចោទ និងដកហូតបានថ្នាំញៀនពីជនជាប់ចោទស៊ីសង្វាក់គ្នាជាមួយចម្លើយរបស់ជនជាប់ចោទគ្រប់ដំណាក់កាល ។ សាលក្រមព្រហ្មទណ្ឌលេខៈ ១៦៦ "ខ១" ក្រ៨ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចផ្ដន្ទាទោសត្រឹមកម្រិតអប្បបរមារួចហើយ ហេតុនេះស្នើសុំតម្កល់ទុកបានការដែល ។ ហេតុនេះក្រុមប្រឹក្សាគប្បីពិចារណា និងសម្រេច ។

៣-តាមការលើកឡើងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងជនជាប់ចោទនាពេលសវនាការសាលាឧទ្ធរណ៍ភ្នំពេញថាៈ

៣.១-ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ និងមេធាវីការពារសិទ្ធិបានលើកឡើងថា: សាលាដំបូងផ្តន្ទាទោសធ្ងន់ធ្ងរពេកសុំតុលាការផ្តល់ស្ថានសម្រាលទោសដល់ខ្លួន ។ ខ្លួនទទួលស្គាល់ចម្លើយដែលបានឆ្លើយនៅសាលាដំបូងឈ្មោះ ណាកាលី គឺជាអ្នកជួលខ្លួនឲ្យដឹកឥវ៉ាន់ឲ្យតាមរយៈទូរស័ព្ទ ខ្លួនមិនដែលបានជួបផ្ទាល់ទេ គេគ្រាន់តែប្រាប់ទីតាំងដែលត្រូវយកគឺផ្សេងៗគ្នា ។ ពេលដែលគាត់ស៊ីយកមក ខ្លួនយកទៅបោះឲ្យម៉ូយភ្លាមៗ ដឹកម្តងទទួលបានប្រាក់ ១០០ដុល្លារ សរុបបានចំនួន៤ លើកហើយ ។ ខ្លួនបានដឹងកំហុងហើយ កម្រៃដែលទទួលបានតិចតួចបំផុត តែ៤០០ ដុល្លារ ប៉ុណ្ណោះ ។ ចំពោះដីឡូត៍លេខ D2 ទំហំ៧០ ម៉ែត្រការ៉េ ដែលតុលាការសម្រេចរឹបអូសនេះគឺជាកម្មសិទ្ធិរបស់ម្តាយខ្លួនដែលបានចំណាយប្រាក់ផ្ទាល់ខ្លួនរបស់គាត់ទិញពីឈ្មោះ [redacted] ឈុនគ្រីមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវតាំងពីឆ្នាំ២០១៤ ។ សំណូមពរសូម បន្ថយទោសឲ្យខ្លួនដោយក្តីអនុគ្រោះ ។ ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា សេចក្តីសន្និដ្ឋាន និងសំណូមពរខាងលើពុំអាចទទួលពិចារណា និងសម្រេចបានទេព្រោះមានលក្ខណៈផ្ទុយនឹងបញ្ញត្តិមាត្រា៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ម្យ៉ាងទៀតការលើកអំពីដីឡូត៍លេខ D2 ទំហំ៧០ម៉ែត្រការ៉េ ដោយជនជាប់ចោទ និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ គឺពុំមានគុណសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ទេ ហេតុនេះសាលាពុំអាចទទួលយកមកពិចារណាបានទេ ។

៣.២-ជនជាប់ចោទឈ្មោះ [redacted] ន្នក និងមេធាវីការពារសិទ្ធិបានលើកឡើងថា: ខ្លួនទទួលស្គាល់ចម្លើយនៅសាលាដំបូង ខ្លួនមិនបានដឹងរឿងទេ គេជួលឲ្យដឹកទទួលបានប្រាក់ចំនួន ៣ ០០០ដុល្លារអាមេរិក កន្លងមកខ្លួនមិនដែលដឹកទេទើបដឹកលើកទី១ ខ្លួនមានមុខរបរជាជាងជួសជុលម៉ូតូ ឡាននោះជួលគេតម្លៃ១០០ដុល្លារដោយសាបញ្ហាកូវីដខ្លួនមិនមានចំណូលគេហៅដឹកឥវ៉ាន់ខ្លួនក៏ព្រម ។ ខ្លួនស្គាល់ឈ្មោះ ពៅ តាមរយៈបងរបស់ខ្លួន គាត់ជាមិត្តភក្តិរបស់បងខ្លួន ដំបូងទាក់ទងតាមទូរស័ព្ទដៃក្រោយមកក៏ទាក់ទងគ្នាតាមឆាត ។ ឡាននេះខ្លួនដឹកឥវ៉ាន់តែ៣ការ៉ុងនេះទេ មិនមានដឹកអ្វីផ្សេងទៀតទេ ។ ចំពោះឈ្មោះ ពិសិដ្ឋ ទើបតែស្គាល់នៅពេលសមត្ថកិច្ចឃាត់ខ្លួននេះទេ ។ ខ្លួនរស់នៅភ្នំពេញ ខ្លួនបើទៅយកឥវ៉ាន់នៅខេត្តក្រចេះ ប៉ុន្តែយប់វង្វេងផ្លូវទៅដល់ខេត្តស្ទឹងត្រែងនៅពេលដែលសមត្ថកិច្ចឃាត់ខ្លួនធ្វើការឆែកឆេរកឃើញថាជាថ្នាំញៀន ។ ខ្លួនទើបតែទទួលបានប្រាក់៥០០ដុល្លារទេ ចំពោះឈ្មោះ [redacted] សួស្តី ខ្លួនទើបតែជួបនៅពេលសមត្ថកិច្ចឃាត់ខ្លួនទេ ។ ខ្លួនមិនដឹងច្បាស់ថាឈ្មោះ [redacted] សួស្តី និងឈ្មោះ ពៅ គឺជាមនុស្សតែម្នាក់ឬអត់ ឥវ៉ាន់នេះគេប្រាប់ថាត្រីងៀត ខ្លួនក៏មិនបានបើកមើលដែរ ។

តាមការលើកឡើងរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទថា: កូនក្តីខ្លួនពុំបានជាប់ពាក់ព័ន្ធជាមួយបទល្មើសសម្អាតប្រាក់ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនទេ ។ ឈ្មោះ ពៅ បានទាក់ ទងមកកូនក្តីខ្លួនតាមរយៈបងជីដូនមួយគាត់ ហើយគាត់ប្រាប់ថាគឺជាត្រីងៀតបើដឹងថាជាថ្នាំញៀនក៏កូនក្តីខ្លួនមិនដឹកដែរ ។ គាត់មានមុខរបរជាជាងជួសជុលម៉ូតូ ដោយសារតែវិបត្តិកូវីដមិនមានចំណូល មានគេជួលទើបគាត់ទៅរកជួលឡានគេដើម្បីមកស៊ីឈ្នួលដឹកឥវ៉ាន់ឲ្យគេ ។ គាត់ក៏មិនបានដឹងថាគេឲ្យដឹកនោះជាថ្នាំញៀនដែរទើបតែ ដឹងនៅពេលសមត្ថកិច្ចឃាត់ខ្លួនប្រាប់ថាចាញ់បោកគេគាត់មានការភ័យយ៉ាងខ្លាំង ។ ឈ្មោះ ពៅ ក៏បានបញ្ជាក់រួចហើយថាគាត់ប្រាប់កូនក្តីខ្លួនថាជាត្រីងៀតមិនមែនជាថ្នាំញៀនទេ ។ កូនក្តីខ្លួនបានឆ្លើយបដិសេធរហូតមកគាត់គ្រាន់តែដឹងឥវ៉ាន់ដែលដឹកជាត្រីញៀតប៉ុណ្ណោះ មិនបានពាក់ព័ន្ធជាមួយបទល្មើសទេហើយក៏ពុំមានភស្តុតាង បញ្ជាក់ថាគាត់មានការពាក់ព័ន្ធទេ សំណូមពរសូមឲ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ ។

<u>ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា</u> សេចក្តីសន្និដ្ឋាន និងសំណូមពរខាងលើពុំមានលក្ខណៈសមស្របតាមអង្គហេតុ និងអង្គច្បាប់អាចឲ្យក្រុមប្រឹក្សាទទួលយកមកពិចារណា និងសម្រេចបានទេ ដោយហេតុថាជនជាប់ចោទបានបានអះអាងថាគេជួលខ្លួនដឹកជាត្រីងៀត មិនបានដឹងថាថ្នាំញៀនទេ ប៉ុន្តែតាមការអះអាងត្រីងៀតតាំងបីការ៉ុងគឺមានតម្លៃប្រហែល មួយលានរៀល ហើយទទួលបានកម្រៃជើងសាររហូតដល់ទៅ ៣ ០០០ដុល្លារដំណោះ ហើយភស្តុតាងជាក់ស្តែងជាថ្នាំញៀនដកហូតបានពីជនជាប់ចោទរូបនេះមានចំនួនយ៉ាងច្រើនសន្ធឹកសន្ធាប់ទៀតផង ព្រមទាំងពុំមានភស្តុតាងដោះបន្ទុកណាមកបញ្ជាក់ជូនដូចការអះអាងរបស់ខ្លួនទេឃើញថា

សេចក្តីសន្និដ្ឋានខាងលើគ្រាន់តែជាការដោះសារតែប៉ុណ្ណោះពុំមានមូលដ្ឋានតាមផ្លូវ ច្បាប់ដែលអាចឲ្យក្រុមប្រឹក្សាទទួលយកមកពិចារណា និងសម្រេចបានទេ ។

៣.៣-ជនជាប់ចោទឈ្មោះ [redacted] សួស្តី បានលើកឡើងថាៈ ខ្លួនទទួលស្គាល់ចម្លើយនៅសាលាដំបូងទុកបានការដដែល ខ្លួនទទួលស្គាល់អង្គហេតុដូចការចោទប្រកាន់មែន ។ គ្រឿងញៀនទាំងនេះគឺយកពីខេត្តស្ទឹងត្រែង ខ្លួនរកស៊ីនេះ ២ ទៅ ៣ ដងហើយ ខ្លួនក៏ស៊ីឈ្នួលដឹកយកឲ្យគេដែរ ទទួលបានកម្រៃមួយជើង ៦ ០០០ ទៅ ៧ ០០០ដុល្លារអាមេរិក ។ ក្រៅពីមុខរបរនេះខ្លួនមិនមានមុខរបរអ្វីផ្សេងទៀតទេ ខ្លួនមានប្រពន្ធកូនហើយ ខ្លួនទើបតែឲ្យឈ្មោះ[redacted]ពន្លក ដឹកជាលើកទី១ ហើយក៏មិនបានប្រាប់ថា ជាអ្វីដែរ ពេលគាត់សួរ ខ្លួនប្រាប់ថា ជាត្រីងៀត ។ ខ្លួនទើបតែឲ្យប្រាក់ថ្លៃឈ្នួលបានចំនួន ៥០០ដុល្លារទេ ត្រីងៀតទាំងនេះមានតម្លៃប្រហែលមួយលានរៀល ។ ខ្លួនស្គាល់ឈ្មោះ[redacted]ពន្លក តាមរយៈបងរបស់វាឈ្មោះ បូរ ដែលជាមិត្តភក្តិរៀនជាមួយគ្នា តែបានស្លាប់បាត់ហើយ ។ ខ្លួនដឹងកំហុសហើយ សន្យាឈប់ប្រព្រឹត្តទៀតហើយ ខ្លួនបញ្ជារចេញពីក្នុងពន្ធនាគារទៅចំពោះសំណុំរឿងមុនផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។ ខ្លួនមានជីវភាពក្រីក្រមានប្រពន្ធកូនក្នុងបន្ទុក ខ្លួនដឹងកំហុសហើយសន្យាកែខ្លួនសូមតុលាការមេត្តាផ្តល់ស្ថានសម្រាលទោសដល់ខ្លួនដោយក្តីអនុគ្រោះ ។ ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា សេចក្តីសន្និដ្ឋាន និងសំណូមពរខាងលើពុំអាចទទួលពិចារណា និងសម្រេចបានទេព្រោះមានលក្ខណៈផ្ទុយនឹងបញ្ញត្តិមាត្រា៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ម្យ៉ាងទៀតជនជាប់ចោទជាមេក្លោងដែលកំពុងជាប់ឃុំខ្លួនពីករណីគ្រឿងញៀន ហើយបានប្រព្រឹត្តបទល្មើសថ្មីទៀតក្នុងពន្ធនាគារ ។

៤-តាមសំអាងហេតុបន្តបន្ទាប់ខាងលើ និងភស្តុតាងទាំងអស់ក្នុងសំណុំរឿងក្រុមប្រឹក្សាយល់ឃើញថាៈ មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ៖

៤.១-ឈ្មោះ[redacted]ពិសិដ្ឋ ភេទប្រុស អាយុ៣៧ឆ្នាំ សញ្ជាតិខ្មែរ(អត្តសញ្ញាណដូចខាងលើ)ពីបទ រក្សាទុក ដឹកជញ្ជូន ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទ សម្អាតប្រាក់ ប្រព្រឹត្តនៅចំណុចរាជធានី ភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា៤០, ៧០, ៧១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤.២-ឈ្មោះ[redacted]ន្លក ភេទប្រុស អាយុ៣១ឆ្នាំ សញ្ជាតិខ្មែរ(អត្តសញ្ញាណដូចខាងលើ) ពីបទ រក្សាទុក ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន និងបទ សម្អាតប្រាក់ ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា៤០, ៧០, ៧១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤.៣-ជនជាប់ចោទឈ្មោះ[redacted]សួស្តី ហៅ ពៅ ភេទប្រុស កើតឆ្នាំ១៩៨២ សញ្ជាតិខ្មែរ(អត្តសញ្ញាណដូចខាងលើ) ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៤រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៥-សំអាងហេតុដូចក្នុងសាលក្រមព្រហ្មទណ្ឌលេខៈ ១៦៦ "ខ១"ក្រ៨ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ គឺមានលក្ខណៈសមស្របតាមអង្គហេតុ និងអង្គច្បាប់ហើយសាលាឧទ្ធរណ៍ភ្នំពេញ ឯកភាពនឹងសំអាងហេតុទាំងនេះមិនចាំបាច់លើកមកសរសេរបញ្ជាក់ជាថ្មីទេ ។

៦-សាលក្រមព្រហ្មទណ្ឌលេខៈ ១៦៦ "ខ១"ក្រ៨ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ សម្រេចតម្កល់សាលក្រមខាងលើនេះទុកជាបានការដដែល ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ដូចខាងក្រោម៖

-លេខ: ២៨៤ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] សួស្តី
-លេខ: ៣៦៩ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ពន្លក
-លេខ: ៣៨៥ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ

គឺត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ: ១៦៦ "ខ១"ក្រ៨ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកបានការដដែល ។

៣-បន្តការឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

៤-សាលដីកានេះបានជំនុំជម្រះ និងប្រកាសជាសាធារណៈនាថ្ងៃអង្គារ ៧កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សួស្តី ឈ្មោះ [redacted] ពន្លក និងឈ្មោះ [redacted] ពិសិដ្ឋ និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

ទុកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ៧កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២
**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**
**ប្រធានក្រុមប្រឹក្សា**

[redacted]



Scanned with CamScanner